**ធម្មទេសនារបស់លោកអភិបាលអូលីវីយេ**
**អភិបូជាអធិដ្ឋាននៅភាម៉ែល**
**ថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៨**
*កុំធ្វើជាមនុស្សលោភលន់*

| |
|---|
| អត្ថបទទី១៖ កណ ៣៧,៣-៤.១២-១៣ក.១៧ខ-២៨<br>ដំណឹងល្អ៖ មថ ២១,៣៣-៤៣.៤៥-៤៦ |

បងប្អូនជាទីស្រឡាញ់!

នៅពេលព្រះយេស៊ូមានពាក្យប្រស្នា ដើម្បីបំភ្លឺដល់ក្រុមបូជាចារ្យ និងខាងគណៈផារីស៊ីអំពីរបៀបដែលគេមិនស្វាគមន៍ព្រះយេស៊ូ។ ព្រះយេស៊ូដែលជាព្រះបុត្រារបស់ព្រះជាម្ចាស់ ព្រះយេស៊ូដែលព្រះជាម្ចាស់បានចាត់ណែនាំឲ្យប្រមូលផលផ្លែនៃជីវិតរបស់ពួកគេ។ ប៉ុន្តែនៅពេលនោះគេបានយល់នូវអ្វីដែលព្រះយេស៊ូនិយាយ ក៏ប៉ុន្តែគេទៅរកមធ្យោបាយដើម្បីសម្លាប់ព្រះយេស៊ូតទៅទៀត និងមធ្យោបាយនេះគេមិនហ៊ានធ្វើឲ្យសម្រេច ដោយសារគេខ្លាចមហាជន។ គេមិនខ្លាចព្រះជាម្ចាស់ គេមិនខ្លាចគេធ្វើខុស ទោះបីគេស្ដាប់ពាក្យប្រស្នានេះ គេមិនព្រួយបារម្ភអំពីរបៀបគេសោះ គេខ្លាចតែមហាជន ដោយសារមហាជនចាត់ទុកព្រះយេស៊ូជាព្យាការីម្នាក់។ ប៉ុន្តែគេមិនខ្លាចព្រះជាម្ចាស់ ទោះបីគេយល់ថា ព្រះយេស៊ូប្រហែលយាងមកដូចកូនប្រុសរបស់ម្ចាស់ចម្ការ ម្ចាស់ចម្ការជាព្រះជាម្ចាស់ផ្ទាល់ ប៉ុន្តែគេមិនខ្លាចព្រះជាម្ចាស់។

ដូច្នេះនៅពេលនេះ យើងត្រូវតែនឹកឃើញដល់ជីវិតរបស់យើង ធ្វើយ៉ាងម៉េចដើម្បីឲ្យយើងភ្ជាប់ជាមួយព្រះជាម្ចាស់ជានិច្ច ដើម្បីស្វាគមន៍ព្រះយេស៊ូដែលកំពុងយាងមកជារៀងរាល់ថ្ងៃនៅក្នុងជីវិតរបស់យើង និងជាពិសេសដើម្បីរស់នៅស្របតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ មានន័យថា ដើម្បីឲ្យជីវិតរបស់យើងមានផ្លែ នៅពេលមានផ្លែហើយឲ្យយើងទុកឲ្យអ្នកផ្សេងច្រូតផ្លែហ្នឹង ដើម្បីប្រគល់ទៅព្រះជាម្ចាស់វិញ។ នៅក្នុងរដូវ៤០ថ្ងៃនេះយើងអរព្រះគុណព្រះជាម្ចាស់សម្រាប់ផ្លែខ្លះៗ ដែលយើងឃើញនៅក្នុងព្រះសហគមន៍របស់យើងដែរ ជាពិសេសបងប្អូនដែលបានធ្វើជំហានទីពីរកន្លងមក យើងមានជាង៧០នាក់ ជាផ្លែដែលព្រះជាម្ចាស់បានជួយរៀបចំរួមជាមួយយើង ដើម្បីឲ្យព្រះសហគមន៍របស់យើងរីកចម្រើន និងឲ្យយើងចេះប្រមូលផ្លែហ្នឹង ឲ្យយើងចេះថែរក្សា។ ជាពិសេសឲ្យយើងណែនាំឲ្យគេមានសេចក្ដីសុខ នៅក្នុងជីវិតដោយដើរតាមព្រះយេស៊ូ។ ដូច្នេះយើងត្រូវតែអធិដ្ឋានសម្រាប់ពួក

គេ អធិដ្ឋានសម្រាប់ប្រទេសរបស់យើងដែរ ដើម្បីឲ្យយើងរៀងៗខ្លួនកុំឲ្យយើងមានចិត្តលោភលន់ កុំឲ្យយើងមានចិត្តចង់បាន។ ដោយសារតាមពិតនៅក្នុងរឿងរបស់ព្រះយេស៊ូមានពាក្យប្រស្នា គឺកសិករហ្នឹងគេចង់បាន ចុងក្រោយបំផុតគេសម្លាប់កូនម្ចាស់ចម្ការ ដោយមូលហេតុតែមួយគឺដោយសារគេដឹងថាប្រសិនបើម្ចាស់ចម្ការអស់កូនប្រុស នោះមរតករបស់គាត់ទៅដល់គេ។ ដូច្នេះគេមិនដឹងខ្លួន គេសុខចិត្តប្រហារជីវិត គេសុខចិត្តសម្លាប់ដោយសារគេចង់បានដីចម្ការនោះ ដោយឥតគិតវែងឆ្ងាយសោះ! ដូច្នេះត្រូវតែអធិដ្ឋានដើម្បីឲ្យសង្គមរបស់យើង កុំឲ្យមនុស្សយើងលោភលន់ពេក ចង់បាននេះចង់បាននោះ និងភ្លេចដល់បងប្អូនឯទៀតៗ និងជាពិសេសភ្លេចដល់ផលប្រយោជន៍ ដល់មនុស្សទាំងអស់។

ខ្ញុំទូលអង្វរព្រះជាម្ចាស់ឲ្យព្រះអង្គបំភ្លឺយើង ដើម្បីឲ្យយើងកែប្រែចិត្តគំនិតរៀងៗខ្លួនឲ្យយើងលះបង់ចោលដើម្បីផលប្រយោជន៍ដល់បងប្អូនឯទៀតៗ និងដើម្បីឲ្យយើងរស់នៅតាមរបៀបព្រះយេស៊ូជានិច្ច។ អាម៉ែន៕